# វិធីដាំគួលែន

## ១. ការរៀបចំរណ្ដៅ:

- ត្រូវជីករណ្ដៅ ៦តឹកបួនជ្រុង និង ជំរៅ ៦តឹក




- រោយកំបោរសប្រមាណ២ស្លាបព្រាបាយ ក្នុងរណ្ដៅ។
- ត្រូវដាក់ផេះ ឬ អង្កាម កំប្លោក ចំបើង ពុកអាចម៍មាន់ឬអាចម៍ជ្រូក ឬអាចម៍ គោមួយស្រទាប់កំរាស់ ១តឹក រួចដាក់ដីពី លើ១តឹក ធ្វើយ៉ាងនេះ រហូតទាល់តែពេញរណ្ដៅ។




- ត្រូវទុករណ្ដៅរៀបចំហើយក្នុងរយៈពេល ២ ទៅ ៣អាទិត្យ។
- ចំងាយពីរណ្ដៅមួយទៅរណ្ដៅមួយមាន ប្រវែង ៨ ម៉ែត្រ។

## ២. ការដាំ:

- កូនគួលែនត្រូវរក្សាផ្សាំទុក ១អាទិត្យមុនដាំ
- ផ្អាកស្រោចទឹក២ថ្ងៃមុនដាំដើម្បីកុំអោយបែកដី និងឫស។
- មុនដាំត្រូវដឹកជញ្ជូនកូនគួលែនដាក់ក្បែររណ្ដៅទាំងអស់។
- ត្រូវបកថង់ចេញធ្វើយ៉ាងណាកុំអោយបែកដី
- កប់កូនគួលែនក្នុងរណ្ដៅដោយធ្វើយ៉ាងណាអោយដីកន្ទោងកូនគួលែនស្មើមាត់រណ្ដៅ រួចយកមែកឈើ ដោតក្បែររណ្ដៅចងទប់ ជាមួយកូនគួលែន។



- លប់ដីបន្តិចម្ដងៗដោយសង្កត់ថ្នមៗ ហាមសង្កត់លើដីកន្ទោងកូនគួលែនដែលបណ្ដាលអោយដាច់ឫស។

## ៣. ការថែទាំ និងដាក់ជី:

- ខែវស្សាត្រូវពូនគល់ការពារទឹកដាំនៅគល់បណ្ដាលអោយរលួយឫស។
- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉ន ដោយប្រើជីអាចម៍មាន់ ឬអាចម៍ជ្រូក ឬអាចម៍គោ លាយជាមួយអង្កាមពុក ចំបើង ឬកំប្លោក រលួយកាយកប់ក្នុងដីធ្វើជាកំពែង។
- ប្រសិនបើកូនគួលែនមានសត្វល្អិតស៊ីត្រួយ ត្រូវប្រើថ្នាំសំលាប់សត្វល្អិត (ណ៉ាត្ញ៉)។



## ៤. ការស្រោចទឹក:

* កូនគូលែនអាយុតិចជាង២ឆ្នាំ ត្រូវស្រោចទឹក ១ដងក្នុង១អាទិត្យនៅរដូវប្រាំង។
* យើងត្រូវស្រោចទឹកតែម្តងគត់នៅពេលវាកំពុងចេញផ្កា។

## ៥. ការកាត់តែងមែក:

* ត្រូវកាត់ត្រួយចុងចេញនៅឆ្នាំទីមួយ។
* ត្រូវកាត់មែកមិនសូវល្អចេញ រៀងរាល់ឆ្នាំដោយទុកតាមប្រព័ន្ធ១-៣-៦-១៨ (ដើម១- មែកធំ៣-ខ្នែងធំ៦ និងខ្នែង ត្រួយ១៨)បើអាចធ្វើបានជាការល្អ។



កាត់តែងមែកតាមប្រព័ន្ធ ១-៣-៦-១៨

* នៅពេល ផ្លែគូលែនមានទំហំប៉ុនមេដៃយើង ត្រូវបាញ់ថ្នាំសំលាប់សត្វល្អិត (ណ៉ាតូ) ទៅលើផ្លែដើម្បីការពារដង្កូវស៊ីផ្លែនៅពេលវាទុំ។



## ៦. ការប្រមូលផល:

* មិនត្រូវបេះផ្លែគូលែនទំលាក់លើដីទេ។
* ត្រូវបេះផ្លែគូលែន អោយមានជាប់ទង ជាការប្រសើ។


ឯកសារពិគ្រោះ៖

- Traing module on fruit tree production, 2013 (គណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ នៅខេត្តតំបន់៣យព្យ)
- បទពិសោធន៍ មួរ បេងលឹម កសិករដាំគូលែន, 2011 (ក្បែរវត្តនិវេសន៍ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ)





ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម


# បទពិសោធន៍ជោគជ័យ ក្នុងការដាំគូលែនរបស់កសិករគំរូ




សហការផលិតដោយ៖

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ខេត្តសៀមរាប

ឆ្នាំ២០១៣



សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោម:

លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧